ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិកោះព្នៅ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# (កក្កដា ២០១៩- មិថុនា ២០២២)

14

| | | |
|---|---|---|
| សហគមន៍នេសាទ | ៖ | ភូមិកោះព្នៅ |
| ភូមិ | ៖ | កោះព្នៅ |
| ឃុំ | ៖ | អូរស្វាយ |
| ស្រុក | ៖ | បូរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ | ស្ទឹងត្រែង |

ខែ កុម្ភៈ ឆ្នាំ២០១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# ភូមិកោះព្នៅ
# សម្រាប់រយៈពេល ៣ ឆ្នាំ
# ( កក្កដា ២០១៩ - មិថុនា ២០២២ )

សហគមន៍នេសាទ ៖ ភូមិកោះព្នៅ
ភូមិ ៖ កោះព្នៅ
ឃុំ ៖ អូរស្វាយ
ស្រុក ៖ បុរីអូរស្វាយសែនជ័យ
ខេត្ត ៖ ស្ទឹងត្រែង

ខែ កុម្ភៈ ឆ្នាំ២០១៩

# មាតិកា

១. ស្ថានភាពទូទៅ ..... ៣
២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ..... ៤
៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ ..... ៥
ក. ទីតាំង ..... ៥
ខ. ដែននេសាទ ..... ៥
គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស និងទីជម្រក(ទីកន្លែងពងកូន ទីកន្លែងរស់នៅ អន្លង់) ..... ៦
ឃ. ធនធានជលផល ..... ៦
៤. ការធ្វើនេសាទ ..... ៦
ក. អ្នកនេសាទ ..... ៦
ខ. ឧបករណ៍នេសាទ ..... ៦
គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ..... ៨
៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៨
ក. ទស្សនៈវិស័យ ..... ៨
ខ. គោលបំណងរួម ..... ៨
គ. គោលបំណងជាក់លាក់ ..... ៨
ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍ ..... ៨
ឃ.១. ធនធានជលផល និងអេកូឡូស៊ី ..... ៨
ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ ..... ១០
ឃ.៣. ការងារគ្រប់គ្រង ..... ១៣
ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... ១៥
ច. យុទ្ធសាស្ត្រ ..... ១៥
តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩-មិថុនា ២០២២) ..... ១៨
តារាងកម្មវិធីការងារប្រចាំឆ្នាំ ២០១៩-កក្កដា២០២២ ..... ២២

## ផែនការគ្រប់គ្រង
## កន្លែងនេសាទសហគមន៍

### ១. ស្ថានភាពទូទៅ

សហគមន៍នេសាទភូមិកោះញ្ញៅ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី ២២ ខែតុលាឆ្នាំ ២០០៩ បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ មានទីតាំងស្ថិតនៅក្នុងភូមិកោះញ្ញៅ ឃុំអូរស្វាយ ស្រុកបូរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសហគមន៍នេសាទសរុបចំនួន ៨០គ្រួសារ ស្មើនឹង ២៣៨នាក់ (ស្រីចំនួន ១២២នាក់) និងមានគណៈកម្មការចំនួន ០៧នាក់ (ស្រីចំនួន០២នាក់)។ សហគមន៍នេសាទភូមិកោះញ្ញៅ ត្រូវបានក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមក សហគមន៍នេសាទក៏អនុវត្តសកម្មភាពសំខាន់ៗរបស់ខ្លួនដូចជាៈ រៀបចំភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍នេសាទ រៀបចំក្រុមល្បាត រៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទ ចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា ចុះល្បាតជាប្រចាំដោយសហការជាមួយសមត្ថកិច្ចជលផល និងអាជ្ញាធរមូលដ្ឋានក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលដែលកើតមាននៅក្នុងកន្លែងនេសាទសហគមន៍ភូមិកោះញ្ញៅ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ីរួមមានការបាត់បង់ពូជត្រីសំខាន់ៗ (ត្រីគល់រាំង,ត្រីត្រសក់..) អន្លង់កាន់តែរាក់ទន្លេរាក់ទៅៗ បាក់ច្រាំងមាត់ទន្លេ ត្រីកាន់តែតិចទៅៗពីមួយឆ្នាំទៅមួយឆ្នាំ មិនសូវសំបូរព្រៃលិចទឹក

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ចំនួនប្រជាពលរដ្ឋក្នុងភូមិកើនឡើងប្រជាពលរដ្ឋ ខ្វះមុខរបរចិញ្ចឹមជីវិត ខ្វះទីផ្សារខ្វះដីធ្វើស្រែ និងលំនៅដ្ឋានខ្វះចំណេះដឹង ជំនាញបច្ចេកទេស និងទុនប្រកបមុខរបរចិញ្ចឹមសត្វ និងដាំដំណាំ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើឧបករណ៍នេសាទខុសច្បាប់ (ប្រើប្រាស់គ្រឿងផ្ទុះ ឧបករណ៍ឆក់ គប់គ្រាប់បែក និងសារជាតិពុល) បទល្មើសភាគច្រើនកើតឡើងនៅពេលយប់ជ្រៅ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការងារសហគមន៍នេសាទនៅមានកំរិត ការចូលរួមរបស់ប៉ូលីសប៉ុស្តិ៍នៅមានកំរិត ជនល្មើសមិនខ្លាចគណៈកម្មការសហគមន៍នេសាទ សហគមន៍នេសាទខ្វះមធ្យោបាយចុះល្បាត និងថវិកាមិនទាន់មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំសហគមន៍នេសាទ គណៈកម្មការសហគមន៍នេសាទមិនទាន់យល់ពីច្បាប់ជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍ច្បាស់ គណៈកម្មការមិនទាន់ស្គាល់ពីតួនាទីខ្លួនឯងច្បាស់លាស់ សហគមន៍នៅគិតថាការងារគណៈកម្មាការជាការងារបច្ចេកទេស និងសមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មការជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីមានស្ត្រីច្រើនចូលរួមក្នុងកិច្ចប្រជុំនានា ប៉ុន្តែការសម្រេចចិត្តរបស់ស្ត្រីនៅមានកម្រិត។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

ក. ប្រជាពលរដ្ឋ

សហគមន៍នេសាទភូមិកោះញ្ជៅ មានចំនួនប្រជាពលរដ្ឋសរុប ១១៤គ្រួសារ ៤៧៩នាក់ (ស្ត្រី ២៣៩នាក់) នៅក្នុងនោះមានជនជាតិខ្មែរចំនួន ១០០%។

- ចំនួនស្ត្រីជាមេគ្រួសារមាន ១៤ នាក់
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ០៩ នាក់
- ចំនួនបុរសពោះម៉ាយក្នុងសហគមន៍នេសាទមាន ០២ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមានប្រុស ០៨ នាក់(ស្រី ០៣ នាក់)
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទ ០៧ នាក់(ស្រី ០២ នាក់)
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ០៩ នាក់ (ស្រី ០៨ នាក់)
- ចំនួនអ្នកមានជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ០១ នាក់ (ស្រី ០១ នាក់)
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន ១០០%។

កម្រិតសិក្សាអប់រំរួមមានអ្នកមិនចេះអក្សរមានចំនួន ៣៧ នាក់ (ស្រី ១៩ នាក់) បឋមសិក្សាចំនួនសរុប ៩៤ នាក់ (ស្រី ៤៩នាក់) អនុវិទ្យាល័យចំនួនសរុប ២៥ នាក់ (ស្រី ១២នាក់) វិទ្យាល័យ ចំនួនសរុប ០៥នាក់(ស្រី ០៣នាក់)។

ខ. មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន ៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ១០០ គ្រួសារ ត្រូវនឹង៩០%
- ធ្វើស្រែចំនួន ១០០ គ្រួសារ ដែលមានទំហំដីចំនួន ៨១ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន ៦១គ្រួសារ (សួនច្បារជាលក្ខណៈគ្រួសារដែលមានទំហំ ៤ x ៦ ម៉ែត្រ)
- លក់ដូរជាអាជីព ០៣គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១០០ % នៃ ១១៤ គ្រួសារក្នុងភូមិទាំងអស់
- ស៊ីឈ្នួលប្រមាណ ១០ នាក់
- ពេទ្យសត្វ ០១ នាក់
- មន្ត្រីរាជការ ០២នាក់ (ស្រី ០០)
- ចំណាកស្រុក ១៧ នាក់ (ស្រី ០៧នាក់)។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិកោះញ្ជៅ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍ភូមិកោះញ្ជៅ មានទំហំ ៥១៤ ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

<u>មានព្រំប្រទល់</u>

- ខាងជើងទល់នឹងពាក់កណ្ដាលទន្លេព្រំប្រទល់សហគមន៍នេសាទភូមិកោះឈើទាលធំ
- ខាងត្បូងទល់នឹងព្រំប្រទល់សហគមន៍នេសាទភូមិអូរស្វាយ និងសហគមន៍នេសាទភូមិកោះឈើទាលតូច
- ខាងកើតទល់នឹងព្រំប្រទល់សហគមន៍នេសាទ ភូមិអូរស្វាយពាក់កណ្ដាលទន្លេមេគង្គត្រង់អន្លង់តាឈុន
- ខាងលិចទល់នឹងព្រំប្រទល់សហគមន៍នេសាទភូមិកោះឈើទាលតូចជិតគោលលេខ១០

ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ភូមិកោះព្នៅ មានវិសាលភាពនៅក្នុងទន្លេមេគង្គ និងរួមទាំងមានៈ អូរចំនួន០២ ប្រលាយចំនួន ០៣ និងអន្លង់ចំនួន០២។

ខ.១.អូរ

| ឈ្មោះអូរ | ទំហំសរុប (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| អូរតាអ៊ុត | ១០០០ | ខែ ០៧ - ខែ ០៨ |
| អូរតាជូ | ១០០០ | ខែ ០៧ - ខែ ០៨ |

ខ.២.ប្រលាយ

| ឈ្មោះប្រលាយ | ទំហំសរុប (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ប្រលាយតាពីន | ២០០ | នេសាទមិនបាន |
| ប្រលាយតាស៊ីម | ៣០០ | នេសាទមិនបាន |
| ប្រលាយតាយេន | ១០០ | នេសាទមិនបាន |

ខ.៣.អន្លង់

| ឈ្មោះប្រលាយ | ទទឹង និងបណ្ដោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់តាឈុន | ២០០ X ២០ | ៤០០០ | ១២ | ៥ |
| អន្លង់តាដែន | ៥០ X ៣០ | ១៥០០ | ៣៥ | ១៥ |

កន្លែងនេសាទសហគមន៍កោះព្នៅ មានព្រៃលិចទឹកទំហំសរុប ៥ ហិកតា ជាប្រភេទព្រៃលិចទឹកចម្រុះ។

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស និងទីជម្រក(ទីកន្លែងពងកូន ទីកន្លែងរស់នៅ អន្លង់)

សហគមន៍នេសាទភូមិកោះព្នៅបានឯកភាពគ្នាយកតំបន់ ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន ០១ គឺអន្លង់តាដែន។

| ឈ្មោះ | ទទឹង និងបណ្ដោយ (ម) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា(ម) | រដូវប្រាំង(ម) |
| អន្លង់តាដែន | ៥០ x ៣០ | ១៥០០ | ២៣ | ១៥ |

ឃ. ធនធានជលផល

ឃ.១. ប្រភេទត្រី

ត្រីរស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លៀញ ឆ្ពួញ ខ្នាន់ផ្តិន ច្រកែង កន្ទ្រប់ ត្រីដំរី កញ្ជុះ ក្រុះ កញ្ច្រូក កាហែ ត្រីលិញ ត្រនេល សណ្តាយ ក្រាយព្រលូង ត្រីស្លឹកឫស្សី ត្រីខ្នឹង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីព្រួសក់ ត្រីគល់រាំង ត្រីអណ្តែង ត្រីក្អែក ត្រីថ្មុ ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីឆ្លាំងហាយ ត្រីឆ្មា ត្រីក្របី ត្រីកន្ត្រងប្រេង ត្រីឫសចេក ត្រីក្អុក ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាស៊ីអ៊ី ត្រីប៉ាវ៉ា ត្រីអាចម៍កុក។

ឃ.២. ប្រភេទវារីសត្វ

ក្តាម ខ្យង ខ្ចៅ គ្រុំ លៀស អណ្តើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីង គីង្គក់។

ឃ.៣. ប្រភេទបក្សី

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ ខ្លាត្រី ក្អែកទឹក ក្អែកគោក។

ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ

ដើមត្រែង ដើមអញ្ចោង ដើមរំចេក ដើមអណ្តែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមធ្នាទឹក ដើមក្តុល ដើមជ្រៃ ដើមព្រីង ដើមញ ដើមព្រុះទឹក ដើមទន្លាត ដើមក្របៅ ដើមចេកទុំ ដើមពោធិ៍ ដើមបន្លាឃ្លេ។

## ៤. ការធ្វើនេសាទ

ក. អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៨៤គ្រួសារ
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទក្នុងសហគមន៍មានចំនួន ៣៤ គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍ចំនួន ០០គ្រួសារ។

ខ. ឧបករណ៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| មងត្រីរៀល | ម៉ែត្រ | ៧០គ្រួសារ x១០០ម = ៧ ០០០ ម៉ែត្រ | | | ក្រឡា ១.៥០-៤ ស.មជម្រៅ ០១-៤ ម | | ក្រឡា ១.៥០-៤ ស.មជម្រៅ ០១-៤ ម | ពេញមួយឆ្នាំ |
| សន្ទូច | ផ្លែ | ០៥គ្រួសារ | | | ផ្លែលេខ | | ផ្លែលេខ | ពេញមួយ |

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើ ប្រាស់ ឧបករណ៍ នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | |
| | | x១០០ផ្លែ =៥០០ផ្លែ | | | ១៥-០៦ | | ១៥-០៦ | ឆ្នាំ |
| លប | គ្រឿង | ២០គ្រួសារ x៥គ្រឿង = ១០គ្រឿង | | | មុខកាត់ ០.៧០ម បណ្តោយ ២.៥០ម | | មុខកាត់ ០.៧០ម បណ្តោយ ២.៥០ម | ខែ៦-១២ |
| សំណាញ់ ត្រីរៀល | វង់ | ២០គ្រួសារ x២ =២០ វង់ | | | សំរុង ៣ - ៣.៥០ម | | សំរុង ៣ - ៣.៥០ម | ពេញមួយ ឆ្នាំ |
| សំណាញ់ ត្រីធំ | វង់ | ១០គ្រួសារ x២ =២០ វង់ | | | សំរុង ៣.៥០ - ៥.៥០ម | | សំរុង ៣.៥០ - ៥.៥០ម | ពេញមួយ ឆ្នាំ |
| ចាន់ | គ្រឿង | ២០គ្រួសារ x៥ =១០០ គ្រឿង | | | ទំហំ ០.៤០ ម ប្រវែង ០.៦០ម | | ទំហំ ០.៤០ ម ប្រវែង ០.៦០ម | ខែ០៦-ខែ ១២ |

ប្រភេទទូកកាណូត

| ប្រភេទទូក កាណូត | ចំនួន | | | ចំណុះ | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ | សមាជិក | មិនមែន សមាជិក | អ្នកខាង ក្រៅភូមិ |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ៧៤ | | | ២-៤ | | | ៧ | | |
| ទូកអេវជាប់ម៉ាស៊ីន HONDA/HINOTA | ០២ | | | ២-៤ | | | ៩ | | |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ០៣ | | | ២-៤ | | | ១៣ | | |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | ០៨ | | ១០ | ៣-៤ | | | ១៨ | | ១៨ |
| ទូកអេវជាប់ម៉ាស៊ីន HINOTA | | | ០៥ | | | ៣-៤ | | | ២០ |

គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១.១៤ | ៩១៩.៩១ | ១,៦៦១.០៦ |
| សរុប | ៧៤១.១៤ | ៩១៩.៩១ | ១,៦៦១.០៦ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទកោះញ្ញៅ មានទស្សនវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ។

គ. គោលបំណងជាក់លាក់

- ការពារព្រៃលិចទឹកជាជម្រកត្រី
- បង្កើនជម្រើសមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ តាមរយៈការចិញ្ចឹមសត្វ ត្រី ដាំបន្លែ និងបណ្ដុះផ្សិត
- កាត់បន្ថយបទល្មើសនេសាទ តាមរយៈការផ្សព្វផ្សាយ និងចុះល្បាត ដោយមានកិច្ចសហការជាមួយ អាជ្ញាធរដែនដី និងអ្នកពាក់ព័ន្ធ។

ឃ. ផែនការសកម្មភាពគ្រប់គ្រងកន្លែងនេសាទសហគមន៍

ឃ.១. ធនធានជលផល និងអេកូឡូស៊ី

ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ១- ក្នុងទន្លេ | នេសាទពេញ | មង | ជម្រៅ១-៤ ម៉ែត្រ ក្រឡា២-៧ស.ម | ១០០ម/គ្រួសារ | |

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| មេគង្គ | មួយឆ្នាំជា លក្ខណៈគ្រួសារ | ចាន់ | មុខកាត់ ០.៤ ម ប្រវែង ០.៦ ម | ៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់០.៧០ម/ប្រវែង២.៥០ម | ៥ គ្រឿង/គ្រួសារ | |
| | | សំណាញ់ត្រីរៀល | សំរុង ៣-៣.៥ ម៉ែត្រ ក្រឡា ១.៥-០២ស.ម | ១វង់/គ្រួសារ | |
| | | សំណាញ់ត្រីធំ | សំរុង ៣-៣.៥ ម៉ែត្រ ក្រឡា ១.៥-០៦ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូចរនង | លេខ១២-០៥ | ១០០ផ្លែ/គ្រួសារ | |
| ២- អូរតាអ៊ុត | ខែ០៧-ខែ០៨ | មង | ជម្រៅ១-៤ ម៉ែត្រ ក្រឡា២-៧ស.ម | ១០០ម/គ្រួសារ | |
| | | ចាន់ | មុខកាត់ ០.៤ ម ប្រវែង ០.៦ ម | ៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់០.៧០ម/ប្រវែង២.៥០ម | ៥ គ្រឿង/គ្រួសារ | |
| | | សំណាញ់ត្រីរៀល | សំរុង ៣-៣.៥ ម៉ែត្រ ក្រឡា ១.៥-០២ស.ម | ១វង់/គ្រួសារ | |
| | | សំណាញ់ត្រីធំ | សំរុង ៣-៣.៥ ម៉ែត្រ ក្រឡា ១.៥-០៦ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូចរនង | លេខ១២-០៥ | ១០០ផ្លែ/គ្រួសារ | |
| ៣- អូរតាជូ | ខែ០៧-ខែ៨ | មង | ជម្រៅ១-៤ ម៉ែត្រ ក្រឡា២-៧ស.ម | ១០០ម/គ្រួសារ | |
| | | ចាន់ | មុខកាត់ ០.៤ ម ប្រវែង ០.៦ ម | ៥គ្រឿង/គ្រួសារ | |
| | | លប | មុខកាត់០.៧០ម/ប្រវែង២.៥០ម | ៥ គ្រឿង/គ្រួសារ | |
| | | សំណាញ់ត្រីរៀល | សំរុង ៣-៣.៥ ម៉ែត្រ ក្រឡា ១.៥-០២ស.ម | ១វង់/គ្រួសារ | |
| | | សំណាញ់ត្រីធំ | សំរុង៣-៣.៥ម៉ែត្រ ក្រឡា១.៥-០៦ស.ម | ១វង់/គ្រួសារ | |
| | | សន្ទូចរនង | លេខ១២-០៥ | ១០០ផ្លែ/គ្រួសារ | |

ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ឈ្មោះដែន នេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍ភូមិកោះញ្ញៅ | បង្គោលព្រំធ្វើពីស៊ីម៉ង់ ចំនួន ០៦បង្គោល | -រៀបចំក្រុមបោះបង្គោល(ឱ្យស្ត្រីនិងបុរសជាគណៈកម្មាការសហគមន៍នេសាទចូលរួមសម្រេចចិត្តក្នុងការកំណត់ទីតាំងបោះបង្គោលព្រំប្រទល់)<br>-ទិញបង្គោលនិងយុទ្ធនាការចុះបោះបង្គោល | ២.៤០០ | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |



| | | | | | | |
|---|---|---|---|---|---|---|
| | | -ផ្សព្វផ្សាយជាសាធារណៈ | | | | |
| | ផ្ទាំងប៉ាណូការនេសាទខុសច្បាប់ ចំនួន ២ផ្ទាំង | ផលិតនិងបោះផ្ទាំងប៉ាណូការនេសាទខុសច្បាប់កន្លែងអភិរក្ស | ១.០០០ | -គណៈកម្មការ<br>-សមាជិកស.ន<br>-មេភូមិ មេឃុំ | ៧/២០១៩ | ៦/២០២២ |

### ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ការថែរក្សាព្រៃលិចទឹកនៅសហគមន៍នេសាទភូមិកោះព្នៅ | ៥ ហិកតា | ព្រៃលិចទឹកដែលត្រូវធ្វើការពារនូវប្រភេទព្រៃចម្រុះ | - ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក ៣០ ស្លាក<br>- ផ្ទាំងប៉ាណូការហាមកាប់ព្រៃលិចទឹក ០២ផ្ទាំង | ៣០០<br>១.០០០ | ៧/២០១៩ | ៦/២០២២ | |

### ឃ.២. ការគាំទ្រជីវភាពប្រជាពលរដ្ឋ

### ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ១០ គ្រួសារបណ្តុះផ្សិតចំបើង | -ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-បណ្តុះផ្សិត និងធ្វើមេផ្សិត<br>-អនុវត្តផ្ទាល់<br>-តាមដានត្រួតពិនិត្យ | ផ្សិតចំបើង | ៣.០០០ | ៧/២០១៩ | ៦/២០២២ |
| ២០ គ្រួសារដាំបន្លែតាមបច្ចេកទេសលក្ខណៈគ្រួសារ | -ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>-វគ្គបណ្តុះបណ្តាលបច្ចេកទេសដាំបន្លែជាលក្ខណៈគ្រួសារនិងអនុវត្តផ្ទាល់<br>-ផ្តល់គ្រាប់ពូជបន្លែ<br>- ត្រួតពិនិត្យនិងតាមដាន | គ្រាប់ពូជបន្លែ (ស្ពៃ ត្រកួន ត្រសក់ សណ្តែក គ្រប់) | ៦.០០០ | ៧/២០១៩ | ៦/២០២២ |
| ៤០ គ្រួសារចិញ្ចឹមមាន់ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត | ពូជក្នុងស្រុក | ១២.០០០ | ៧/២០១៩ | ៦/២០២២ |

| | | | | | |
|---|---|---|---|---|---|
| តាមបច្ចេកទេសជាគ្រួសារ | - បណ្តុះបណ្តាលចិញ្ចឹមមាន់តាមបច្ចេកទេស ជាលក្ខណៈគ្រួសារ<br>- អនុវត្តជាក់ស្តែងជាមួយគ្រួសារកសិករ ធ្វើទ្រុង ផ្តល់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យ | | | | |
| ២០ គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសជាគ្រួសារ | - ជ្រើសរើសគ្រួសារកស្ម័គ្រចិត្ត<br>- បណ្តុះបណ្តាលចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ<br>- អនុវត្ត ជាក់ស្តែងជាមួយគ្រួសារកសិកររៀបចំជ្រើសរើស ធ្វើទ្រុង និងផ្តល់ពូជ<br>- តាមដានត្រួតពិនិត្យ | ពូជក្នុងស្រុក | ៦.០០០ | ៧/២០១៩ | ៦/២០២២ |
| ៨០ គ្រួសារចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្តល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ២៤.០០០ | ៧/២០១៩ | ៦/២០២២ |
| ៤០ គ្រួសារចិញ្ចឹមក្របីតាមបច្ចេកទេសជាគ្រួសារ | - ជ្រើសរើសគ្រួសារស្ម័គ្រចិត្ត<br>- បង្កើតគោលការណ៍<br>- ផ្តល់ពូជ<br>- ត្រួតពិនិត្យតាមដាន | ពូជក្នុងស្រុក | ១២.០០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ (ក្បាល) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|---|
| | | | | | | ចាប់ផ្តើម | ប្រមូលផល |
| ១០ គ្រួសារចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ (១០គ្រួសារ/ឆ្នាំ) | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីជាគ្រួសារ<br>-ជីកស្រះនិងដាក់កូនត្រីចិញ្ចឹម<br>-ត្រួតពិនិត្យតាមដាន | ស្រះទំហំ ១០ម x ៣០ម | ៣.០០០ | ត្រីអណ្តែង ត្រីទីឡាព្យា ត្រីរ៉ស់... | ៨.០០០ | ៧/២០១៩ | ៦/២០២២ |

ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់

ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ ១ ក្រុម | • ផ្សព្វផ្សាយទស្សនៈក្រុមសន្សំដល់សហគមន៍<br>• ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសប្រធានក្រុម<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• ផ្តល់ទុនដល់ក្រុម<br>• តាមដានត្រួតពិនិត្យ | ៧/២០១៩ | ៦/២០២២ | |

ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចត្រូវ បានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ជួសជុលផ្លូវលំក្រាលគ្រួសក្រហម/ដីសក្នុងភូមិ (២កន្លែង) | ០៦ គីឡូម៉ែត្រ | ១០.០០០ | ៧/២០១៩ | ៦/២០២២ |
| សាង់សង់ស្ពានឈើឆ្លងអូរ ១ កន្លែង | ២ម៉ X ២៥ម៉ | ១០.០០០ | ៧/២០១៩ | ៦/២០២២ |
| លូដោះទឹក | ៣កន្លែង | ៩.០០០ | ៧/២០១៩ | ៦/២០២២ |
| ផ្ទាំងសូឡា | ២កន្លែង | ២.០០០ | ៧/២០១៩ | ៦/២០២២ |

ឃ.២.៥.ផែនការទាក់ទងនឹងការរកទីផ្សារ

ផែនការទាក់ទងនឹងការរកទីផ្សារ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទ | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|
| ចងក្រងក្រុម និងស្វែងរកឈ្មួញ | • ជ្រើសរើសអ្នកទទួលផល<br>• បោះឆ្នោតជ្រើសរើសមេដឹកនាំក្រុម<br>• កំណត់ក្រុមឈ្មួញ<br>• តាមដានត្រួតពិនិត្យ | ៧/២០១៩ | ៦/២០២២ | |

ឃ.៣. ការងារគ្រប់គ្រង

ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការ សកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | តម្រូវការសម្ភារ | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| សហគមន៍ចុះល្បាតដោយខ្លួនឯង | | ៥ដង/១ខែ | | ៧/២០១៩ | ៦/២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | ៣ដង/១ខែ | ៤.៥០០ | ៧/២០១៩ | ៦/២០២២ |
| បំពាក់សម្ភារល្បាត (១ ឈុត) | អាវពោង | ១២ អាវ | ១.០០០ | ៧/២០១៩ | ៦/២០២២ |
| | អាវភ្លៀង | ១២ អាវ | | | |
| | គោមបំភ្លឺពាក់ក្បាល | ១២ គោម | | | |
| | ភ្លើងហ្វារ និងអាគុយ | ២ ឈុត | | | |
| | វិទ្យុទាក់ទង | ៤ គ្រឿង | | | |
| | កែវយឺត | ២ គ្រឿង | | | |
| | ម៉ាស៊ីនថត | ១ គ្រឿង | | | |
| | អង្រឹង | ១២ អង្រឹង | | | |
| | តង់គ្របទូក ៤មគុណ៦ម | ២ តង់ | | | |
| | សម្ភារត្រួតពិនិត្យទឹក | ១ កំប្លេ | | | |
| | ស្លាបចក្រ | ៨ គ្រឿង | | | |
| | សោរសម្រាប់ជួសជុលទូក | ១ សម្រាប់ | | | |
| | សោរច្រវាក់ចាក់ទូក | ២ សោរ | | | |
| | អាវយឺត | ៣៦អាវ | | | |
| ទិញទូកស្ពាចម៉ាស៊ីន | | ២ គ្រឿង | ៣.០០០ | ៧/២០១៩ | ៦/២០២២ |
| ប្រេងសម្រាប់ល្បាត | | ៦០ លីត្រ/ខែ | | ៧/២០១៩ | ៦/២០២២ |
| សេវាជួសជុលថែទាំទូកម៉ាស៊ីន | | ២ ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | ដីប្រធានសហគមន៍នេសាទ | ១ កន្លែង | ៣.០០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១ដង/១ខែ | | ៧/២០១៩ | ៦/២០២២ |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | ១ដង/១ខែ | | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាល របាយការណ៍ និងរៀបចំទុកឯកសារ | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| បណ្តុះបណ្តាលអំពីការដោះស្រាយទំនាស់ | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីជំនាញសម្របសម្រួល | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |
| បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាព | ១លើក/១ឆ្នាំ | ៥០០ | ៧/២០១៩ | ៦/២០២២ |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្រៅខេត្ត | ១លើក/១ឆ្នាំ | ១៣.៥០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | ៣ដង/ឆ្នាំ | ១.២០០ | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | ២ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយដែននេសាទសហគមន៍ | ៣ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | ២ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងសារប្រយោជន៍ធនធានជលផល | ១ដង/ឆ្នាំ | | ៧/២០១៩ | ៦/២០២២ |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ២ដង/ឆ្នាំ | ៩០០ | ៧/២០១៩ | ៦/២០២២ |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មាការសហគមន៍នេសាទ | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | ៧/២០១៩ | ៦/២០២២ | គណៈកម្មាការសហគមន៍នេសាទ | ៣០០ |

ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (រៀល) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានសមាជិកភាព | ចុះប្រមូលប្រាក់សមាជិកភាព | ៧/២០១៩ | ៦/២០២២ | | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ៧/២០១៩ | ៦/២០២២ | ៩៤.៥ | |
| ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ | ៧/២០១៩ | ៦/២០២២ | 0 | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | ៨.១០០ | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ៧/២០១៩ | ៦/២០២២ | ១១១.៣២៥,៥ | |

ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្ដើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ | ថវិកា (ដុល្លារ) |
|---|---|---|---|---|
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | ៧/២០១៩ | ៦/២០២២ | គណៈកម្មការ សហគមន៍ នេសាទ | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំដោយមានការចូលរួមពីស្ត្រី | ៧/២០១៩ | ៦/២០២២ | គណៈកម្មការ សហគមន៍ នេសាទ | ៦០០ |

ច. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោម ៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមាន ៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ជ្រើសរើសស្ត្រីមេគ្រួសារ និងស្ត្រីចំនួនយ៉ាងតិច ៧% ចូលរួមក្នុងសកម្មភាពទ្រទ្រង់ជីវភាពរស់នៅ
- អញ្ជើញស្ត្រីជាសមាជិកសហគមន៍នេសាទចូលរួមយ៉ាងតិច៤០% ក្នុងការបណ្តុះបណ្តាល សិក្ខាសាលា និងសកម្មភាព ទ្រទ្រង់ជីវភាពរស់នៅ និងវារីវប្បកម្ម
- ស្ត្រីកម្មករគ្មានជំនាញជាសមាជិកសហគមន៍នេសាទ៤០%ចូលរួមសកម្មភាពហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច
- អញ្ជើញស្ត្រីមេគ្រួសារ និងស្ត្រីជនជាតិដើមភាគតិចជាសមាជិកសហគមន៍នេសាទ ចូលរួមប្រជុំ និងចូលរួមសកម្មភាពនានា និងចូលជាគណៈកម្មការរបស់សហគមន៍នេសាទ
- ជ្រើសរើសស្ត្រីជាសមាជិកសហគមន៍នេសាទ ៥០% ចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព
- ផ្តល់ឱកាសស្ត្រី៥០%ជាសមាជិកសហគមន៍នេសាទចូលរួមក្នុងសកម្មភាពគាំទ្រជីវភាព និងទទួលផលប្រយោជន៍ពីគម្រោងក្នុងនោះស្ត្រីជាមេគ្រួសារ៧%
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការចូលរួមក្នុងការសម្រេចចិត្តនានា
- លើកទឹកចិត្តស្ត្រីជាគណៈកម្មាការមិនបោះបង់ចោលការងារ
- រៀបចំការប្រជុំឱ្យសមស្របនឹងពេលវេលារបស់ស្ត្រី ដែលមានលទ្ធភាពចូលរួម
- ជំរុញឱ្យមានស្ត្រីយ៉ាងតិច២៥% ជាសមាជិកគណកម្មាការសហគមន៍នេសាទ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល ៣ ឆ្នាំ (កក្កដា ២០១៩-មិថុនា ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **យ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | |
| យ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំ ពេលវេលា ទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ ២ ដង ក្នុង០១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ១២០ | អង្គការដៃគូ រ.ជលផល សហគមន៍ | ៦/២០១៩ | ៧/២០២២ | |
| យ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ចំនួន ០៦ បង្គោល | មានបង្គោល ០៦ បង្គោល | ២.៤០០ | អង្គការដៃគូ រ.ជលផល អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| | តម្លើងផ្ទាំងប៉ាណូផែនទីស/ហនេសាទ ចំនួន ០២ផ្ទាំង | មានផ្ទាំងប៉ាណូ ០២ ផ្ទាំង | ១.០០០ | | ៦/២០១៩ | ៧/២០២២ | |
| យ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក ចំនួន ៣០ស្លាក | មានស្លាក ៣០ ស្លាក | ៣០០ | អង្គការដៃគូ រ.ជលផល | ៦/២០១៩ | ៧/២០២២ | |
| | ផ្ទាំងប៉ាណូការហាមកាប់ព្រៃលិចទឹក ០២ផ្ទាំងនៅទីប្រជុំជន | មានផ្ទាំងប៉ាណូ ០២ ផ្ទាំង | ១.០០០ | | | | |
| **យ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | |
| យ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់៤០ គ្រួសារ | ១២.០០០ | អង្គការដៃគូ រ.ជលផល | ៦/២០១៩ | ៧/២០២២ | |
| | ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមគោ ៨០ គ្រួសារ | ២៤.០០០ | | ៦/២០១៩ | ៧/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
| --- | --- | --- | --- | --- | --- | --- | --- |
| | ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមក្របី ៤០ គ្រួសារ | ១២.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | ចិញ្ចឹមជ្រូកតាម បច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូក ២០គ្រួសារ | ៦.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | មានគ្រួសារដាំបន្លែ ៣០ គ្រួសារ | ៩.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | បណ្តុះផ្សិតចំបើង | មានគ្រួសារបណ្តុះផ្សិត ១០ គ្រួសារ | ៣.០០០ | | ៦/២០១៩ | ៧/២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រី ១០ គ្រួសារ | ៣.០០០ | អង្គការដៃគូ រ.ផលផល | ៦/២០១៩ | ៧/២០២២ | |
| ឃ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | ពង្រឹងក្រុមសន្សំប្រាក់ដែលមានស្រាប់ | មានក្រុមសន្សំ ០១ ក្រុមសន្សំប្រាក់បានបង្កើត | | អង្គការដៃគូ សហគមន៍ | ៦/២០១៩ | ៧/២០២២ | |
| ឃ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | ជួសជុលផ្លូវលំក្រាលក្រួសក្រហម/ដីសក្នុងភូមិ ២កន្លែង | មានផ្លូវលំគ្រួសក្រហម ០៦ គីឡូម៉ែត្រ (២កន្លែង) | ១០.០០០ | អង្គការដៃគូ រ.ផលផល អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| | សាង់សង់ស្ពានឈើឆ្លងអូរក្នុងភូមិ | មានស្ពានឈើ ១ កន្លែង (២ម៉ X ២៥ម៉) | ១០.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | លូដោះទឹក | មានលូដោះទឹក ៣កន្លែង | ៣.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | ផ្ទាំងសូឡា | មានផ្ទាំងសូឡា ២កន្លែង | ២.០០០ | | ៦/២០១៩ | ៧/២០២២ | |
| ឃ.២.៥.ផែនកាទាក់ទងនិងការរកទីផ្សារ | ចងក្រងក្រុម និងស្វែងរកឈ្មួញ | ០១ ក្រុម | | អង្គការដៃគូ អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |



tl

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពថវិកា | ពេលចាប់ផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| យ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត ៥ដង/ខែ | ៤.៥០០ | អង្គការនានា រ.ជលផល | ៦/២០១៩ | ៧/២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | បានចុះល្បាត ៣ដង/១ខែ សហការជាមួយអាជ្ញាធរមូលដ្ឋាន | | | ៦/២០១៩ | ៧/២០២២ | |
| | ប្រេងសម្រាប់ល្បាត | មានប្រេង ៦០លីត្រ/១ខែ | | | | | |
| | សេវាជួសជុលថែទាំទូក និងម៉ាស៊ីន | បានជួសជុលទូក និងម៉ាស៊ីន ២ដង/ឆ្នាំ | | | | | |
| | បំពាក់សម្ភារល្បាត | មានសម្ភារៈល្បាត ១ឈុត | ១.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | ទិញទូកស្នាច់ម៉ាស៊ីន | មានទូកម៉ាស៊ីន ចំនួន ២គ្រឿង (១តូច ១ធំ) | ៣.០០០ | | ៦/២០១៩ | ៧/២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | ស្នាក់ការចំនួន១ ត្រូវសាងសង់ | ៣.០០០ | | ៦/២០១៩ | ៧/២០២២ | |
| យ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ | | អង្គការដៃគូ រ.ជលផល អាជ្ញាធរឃុំ សហគមន៍ | ៦/២០១៩ | ៧/២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយឃុំ | បានប្រជុំ១ដង/១ខែជាមួយឃុំ | | | ៦/២០១៩ | ៧/២០២២ | |
| | បណ្ដុះបណ្ដាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | -មានវគ្គបណ្ដុះបណ្ដាល លើមុខជំនាញនីមួយៗ១លើក/ឆ្នាំ<br>-សមត្ថភាពសហគមន៍នេសាទបានប្រសើរឡើង<br>-គណៈកម្មការសហគមន៍នេសាទអាចអនុវត្តន៍បាន | ៥០០ | | ៦/២០១៩ | ៧/២០២២ | |
| | បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | | ៥០០ | | ៦/២០១៩ | ៧/២០២២ | |
| | បណ្ដុះបណ្ដាលអំពីការដោះស្រាយទំនាស់ | | ៥០០ | | ៦/២០១៩ | ៧/២០២២ | |
| | បណ្ដុះបណ្ដាលអំពីរបៀបសរសេរ | | ៥០០ | | ៦/២០១៩ | ៧/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | គម្រោងសំណើ | | | | | | |
| | បណ្តុះបណ្តាលអំពីភាពជាអ្នកដឹកនាំ | | ៥០០ | | ៦/២០១៩ | ៧/២០២២ | |
| | បណ្តុះបណ្តាលជំនាញសម្របសម្រួល | | ៥០០ | | ៦/២០១៩ | ៧/២០២២ | |
| | បណ្តុះបណ្តាលអំពីការរៀបចំផែនការសកម្មភាពការងារ | | ៥០០ | | ៦/២០១៩ | ៧/២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្រៅខេត្ត | -បានទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍១លើក/ឆ្នាំ<br>-បានទទួលនូវបទពិសោធន៍ល្អ | ១៣.៥០០ | | ៦/២០១៩ | ៧/២០២២ | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | បានផ្សព្វផ្សាយ ៣ដង/ឆ្នាំ | ១.២០០ | អង្គការដៃគូ រ.ជលផល អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍ | បានផ្សព្វផ្សាយ ២ដង/ឆ្នាំ | | | ៦/២០១៩ | ៧/២០២២ | |
| | ផ្សព្វផ្សាយដែននេសាទនិងកន្លែងអភិរក្សសហគមន៍ | បានផ្សព្វផ្សាយ ៣ដង/ឆ្នាំ | | | ៦/២០១៩ | ៧/២០២២ | |
| | ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | បានផ្សព្វផ្សាយ ២ដង/ឆ្នាំ | | | ៦/២០១៩ | ៧/២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | បានផ្សព្វផ្សាយ ២ដង/ឆ្នាំ | | | ៦/២០១៩ | ៧/២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | បានផ្សព្វផ្សាយ ១ដង/ឆ្នាំ | | | ៦/២០១៩ | ៧/២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរស ស្ត្រីក្នុងសហគមន៍នេសាទ សមភាព និងសមធម៌យេនឌ័រ | បានផ្សព្វផ្សាយ ២ដង/ឆ្នាំ | ៩០០ | | ៦/២០១៩ | ៧/២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពថវិកា | ពេលចាប់ផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទានមហាសន្និបាតប្រចាំឆ្នាំ | បានផ្សព្វផ្សាយ ២ដង/ឆ្នាំ | | អង្គការដៃគូ រ.ដលផល អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ៣០០ | អង្គការដៃគូ រ.ដលផល អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ភាគទានពីសមាជិកសហគមន៍ | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព | ៩៤.៥ | ថវិកាសហគមន៍ | ៦/២០១៩ | ៧/២០២២ | |
| | ភាគទានប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ ១ឆ្នាំម្តង | ៨.១០០ | | ៦/២០១៩ | ៧/២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (អំណោយពីរាជរដ្ឋាភិបាល អំណោយពីសប្បុរសជន ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | ១១១,៣២៥.៥ | | ៦/២០១៩ | ៧/២០២២ | |
| ង. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | -បានប្រជុំ៤ត្រីមាស/ឆ្នាំ<br>-ទទួលបានរបាយការណ៍និងធ្វើការវាយតម្លៃ | | អង្គការដៃគូ រ.ដលផល អាជ្ញាធរឃុំ | ៦/២០១៩ | ៧/២០២២ | |
| | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី | -បានប្រជុំមហាសន្និបាត១ដង/ឆ្នាំ<br>-ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារ និងលើក ផែនការបន្ត | ៦០០ | | ៦/២០១៩ | ៧/២០២២ | |



th

# តារាងកម្មវិធីការងារប្រចាំឆ្នាំ មិថុនា ២០១៩-កក្កដា ២០២២

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | x | | | | | | | x | | | | | x | | | | | | | x | | | | | x | | | | | | | x | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បោះបង្គោលព្រំធ្វើពីស៊ីម៉ង់ ចំនួន០៦ បង្គោល | | | | | | | | | x | x | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីស/ហ នេសាទ ចំនួន ០២ផ្ទាំង | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្ទាំងប៉ាណូការហាមកាប់ព្រៃលិចទឹក ០២ផ្ទាំងនៅទីប្រជុំជន | | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹក ចំនួន ២០ស្លាក | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសគ្រួសារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចិញ្ចឹមគោតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ចិញ្ចឹមក្របីតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាគ្រួស | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| រៀបចំសួនបន្លែតាមលគ្រួសារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| បណ្តុះផ្សិតចំបើង | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| យ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រី អណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| យ.២.៣. ផែនការរៀបចំ និងពង្រឹងក្រុមសន្សំប្រាក់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ពង្រឹងក្រុមសន្សំមានស្រាប់ | x | x | x | x | x | x | | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| យ.២.៤. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលផ្លូវលំក្រាលក្រួសក្រហម/ដីសក្នុងភូមិ ២កន្លែង | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| សាង់សង់ស្ពានឈើឆ្លងអូរក្នុងភូមិ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| លូដោះទឹក | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ផ្ទាំងសូឡា | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| [illegible]៥.ផែនការទាក់ទងនឹងការរកទីផ្សារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| [illegible]ក្រុម និងស្វែងរកឈ្មួញ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| [illegible] ការងារគ្រប់គ្រង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| បំពាក់សម្ភារល្បាត | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្នាច់ម៉ាស៊ីន | x | x | x | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| សេវាជួសជុលថែទាំទូកម៉ាស៊ីន | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| សាងសង់ទីស្នាក់ការសហគមន៍ | | | | | | | | | | x | x | x | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| បណ្តុះបណ្តាលអំពីរបៀបធ្វើកំណត់ហេតុ សរសេរលិខិតរដ្ឋបាលនិងរបាយការណ៍ | | | | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | | | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | | |
| បណ្តុះបណ្តាលការដោះស្រាយទំនាស់ | | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | | | |
| បណ្តុះបណ្តាលអំពីរបៀបសរសេរ | | | | | | | | | x | | | | | | | | | | | x | | | | | | | | | | | | x | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| គម្រោងសំណើ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | |
| បណ្តុះបណ្តាលការរៀបចំផែនការ | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | |
| ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃ ក្នុងសហគមន៍នេសាទ | | | | x | | x | | | x | | | | | | | x | | x | | | x | | | | | | | x | | x | | | x | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងស.ន | | | | x | | | | | x | | | | | | | x | | | | | x | | | | | | | x | | | | | x | | | |
| ផ្សព្វផ្សាយផែននេសាទនិងកន្លែងអភិរក្សសហគមន៍ | | | | x | x | | | | x | | | | | | | x | x | | | | x | | | | | | | x | x | | | | x | | | |
| ផ្សព្វផ្សាយពីការប្រមូលប្រាក់បដិភាគ | | | | x | | | | | | | x | | | | x | | | | | | | | x | | | | x | | | | | | | | x | |
| ផ្សព្វផ្សាយច្បាប់ជលផល និងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | x | | | | x | | | | | | | | x | | | | x | | | | | | | | x | | | | x | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងសារប្រយោជន៍ធនធានជលផល | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់ស្ត្រីក្នុងសហគមន៍នេសាទ | | | | | | | | | x | x | | | | | | | | | | | x | x | | | | | | | | | | | x | x | | |
| ឃ.៣.៤. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |



tle

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៩ | | | | | | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | |
| | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ភាគទានពីសមាជិកសហគមន៍ | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ភាគទានប្រចាំឆ្នាំ | | | | | | | | | | | x | | | | | | | | | | | | x | | | | | | | | | | | | x | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអំណោយសប្បុរសជន | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x | x |
| ង. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យ មហាសន្និបាតប្រចាំឆ្នាំ | | | | x | x | | | | | | | | | | | x | x | | | | | | | | | | | x | x | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | x | x | | | | | | | | | | | x | x | | | | | | | | | | | x | x | | | | | | | | |
| ច. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្ទៃក្នុង ប្រចាំត្រីមាសរបស់គណៈកម្មការសហគមន៍នេសាទ | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x | | | x |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ មានការចូលរួមពីស្ត្រី | | | | | | x | x | | | | | | | | | | | | x | | | | | | | | | | | | x | | | | | |

លេខ : ០៦០/១៩

បានឃើញ និងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ថាឡាបរិវ៉ាត់ ថ្ងៃទី២៤ ខែ តុលា ឆ្នាំ ២០១៩

ជ. នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

រឿន ហ៊ីង

លេខ : ៣៩០/១៩ ឃ.រ.អ.ស

បានឃើញ និងបញ្ជូនមក

លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ឃុំអូរស្វាយ ថ្ងៃទី.........ខែ តុលា ឆ្នាំ ២០១៩

មេឃុំអូរស្វាយ

សេក ម៉ៅ

សូមគោរពជូន

លោកមេឃុំ អូរស្វាយ

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ភូមិកោះព្នៅ ថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០១៩

ប្រធានគណៈកម្មការសហគមន៍នេសាទ

ភូមិកោះព្នៅ

ជាវ ប៊ុយ

លេខ : ៧២១២

បានឃើញ និងឯកភាព

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៩

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន

លេខ : ២៤០.អកប

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០១៩

ប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

លៀង-សេង

លេខ : ០៤៥/១៩ ខ.រ.ជ.ស.ត

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

" ដើម្បីជូនពិនិត្យ និងសម្រួល"

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ស្ទឹងត្រែង ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០១៩

នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង

ទុំ នីរ៉ូ